



ការផ្សាយរបស់ក្រុមការងារផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម
កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ASDP, ADB

Loan 2022-CAM{SF}

ឆ្នាំ2010

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# បទពិសោធន៍ចិញ្ចឹមគោ
# កសិករ ប៊ុច ប៊ុនថន



នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ASDP, ADB

Loan 2022-CAM{SF}

ឆ្នាំ2010



# បទពិសោធន៍ចិញ្ចឹមគោ
# កសិករ ប៉ិច ប៊ុនថន

ភូមិទី៨ សង្កាត់ខ្សាច ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

នៅព្រះរាជាណាក្រកម្ពុជាបច្ចុប្បន្ន ដីស្រែចំនួន ៨៧ ភាគរយ នៃផ្ទៃដីធ្វើស្រែសរុបកំពុងត្រូវបានប្រើប្រាស់ គោ-ក្របី ជាកំលាំងអូសទាញសម្រាប់ភ្ជួររាស់ នេះបើយោងតាមស្ថិតិកសិកម្មឆ្នាំ ២០០០-២០០១។ មិនតែប៉ុណ្ណោះគោក្របីក្រៅពីជាកំលាំងអូសទាញ គឺថែមទាំងបានផ្តល់នូវលាមករាប់សែនតោន ក្នុងមួយឆ្នាំៗ សម្រាប់ប្រើប្រាស់ធ្វើជាជីដើម្បីបង្កើនគុណភាពដីសម្រាប់ការដុះលូតលាស់ដល់ដំណាំគ្រប់ប្រភេទទៀតផង ។ បន្ថែមលើសពីនេះទៀត គោ ក្របី ជ្រូក មាន់ ទា ត្រូវបានចិញ្ចឹមសម្រាប់លក់ដូរយ៉ាងមានប្រសិទ្ធភាពជាពិសេសនៅពេលដែលកសិករត្រូវការថវិកាចាំបាច់ភ្លាមៗអំឡុងពេលដែលស្រូវមិនទាន់បានប្រមូលផល ឬក៏នៅពេលផលស្រូវមិនអាចធានានូវការហូបចុកពេញមួយឆ្នាំ ដែលបណ្តាលមកពីបាតុភូតធម្មជាតិផ្សេងៗដូចជា ភាពរាំងស្ងួត ទឹកជំនន់ ។ល។ មួយចំណែកទៀតការចិញ្ចឹមសត្វបានដើរតួនាទីយ៉ាងសំខាន់ផងដែរ ហើយដែលមិនអាចជៀសវាងបាននោះ គឺការរួមចំណែកក្នុងការធានា និងលើកកម្ពស់សុវត្ថិភាពស្បៀងដែលផ្តល់នូវប្រភពប្រូតេអ៊ីនសម្រាប់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានផងដែរ ។ ទាំងនេះគឺជាហេតុផលយ៉ាងសំខាន់សំរាប់ក្នុងការជំរុញឱ្យកសិករ **ប៉ិច ប៊ុនថន** ចាប់យកមុខរបរចិញ្ចឹមគោម្យ៉ាងទៀតដោយគាត់យល់ថា :

- គោជាសត្វស្លូតបូតងាយចិញ្ចឹមចំណាយដើមទុនតិច
- លក់បានតម្លៃខ្ពស់
- សំរាប់បន្តពូជ





- លាមកគោ ដាក់ចូលឡជីវឧស្ម័ន ជាថាមពលឯករាជ្យ បំភ្លឺនៅពេលយប់
- ដាំបាយជំនួសហ្គាស់ និងអុសធ្យូង
- លាមកគោធ្វើជាជី ( កាកសំណល់ចេញពីឡ)
- ជំនួសជីគីមីប្រើប្រាស់លើដំណាំគ្រប់ប្រភេទ
-ផលិតផលមានរស់ជាតិ គុណភាព និង តម្លៃខ្ពស់
- បង្កើនគុណភាពដី
- មិនប៉ះពាល់សុខភាព

## ១. ការចាប់ផ្តើមមុខរបរ

- ចាប់ផ្តើមចិញ្ចឹមនៅ ឆ្នាំ ១៩៨៤
- ចំនួនគោមេ ១ក្បាល
- ទិញតម្លៃ ៨ ជីមាស
- ដល់ចន្លោះឆ្នាំ ១៩៨៤-១៩៩៧ គោកើនបាន ចំនួន ៣២ ក្បាល
- បច្ចុប្បន្ន មានគោចំនួន ៥៦ ក្បាល :
- ចិញ្ចឹមខ្លួនឯង ៣៩ ក្បាល ( មេពូជ ១៩ ក្បាល)
- ប្រវាស់  ១៧ ក្បាល ( មេពូជ ១៧ ក្បាល)

## ២. ការរៀបចំចិញ្ចឹម

ក- គ្រោល

- ធ្វើពីឈើប្រក់សង្កសី
- មានរបា
- មានមុងការពារមូស
- មានស៊ុម ដាក់ស្មៅ
- មានពាងទឹក ដិកល់ទឹក

ខ-ពូជ

- កូនកាត់ក្នុងស្រុក
- ពណិស
- ៣ ឆ្នាំ កូន ២
- គ្មានជំងឺឆ្លង
- បានចាក់ថ្នាំការពារទៀងទាត់

គ- ចំណី

- នៅតាមទីវាល
- ស្ដុកចំបើង







- ដំណាំចំណីសត្វ
- ចំបើងផ្អាប់
- ចំណីលាយដោយដៃ មាន :
    - ដើមចេក ស្មៅ ដើមសណ្តែក,,,

## ឃ- ការថែទាំ

- អនាម័យក្រោល មានមុង
- តាមដានសុខភាព និងព្យាបាល
- ផ្តល់ចំណីគ្រប់គ្រាន់ និងមានជីវជាតិ
- ផ្តល់ទឹកស្អាតគ្រប់គ្រាន់
- លាងទឹក និងពិនិត្យថៃ អង្កែ
- ទំលាក់ព្រូន ១ឆ្នាំ ១-២ ដង

## ង- ការចាក់ថ្នាំការពារ

- ចាក់ការពារជំងឺសារទឹក ២ ដងក្នុងឆ្នាំ ( មករា ឬ កក្កដា)
- ចាក់ការពារអុតក្តាម ១ ដង ក្នុងឆ្នាំ ( ធ្នូ)

# ៣- បង្កើនចំនួនសត្វ

- បង្កើនមេពូជឱ្យបាន ២៥ក្បាល ចិញ្ចឹមដោយខ្លួនឯង
- ប្រវាស់ទៅអ្នកផ្សេងឱ្យបានចំនួន ៣០ ក្បាល









## ៤_ ត្រៀមផ្គត់ផ្គង់ចំណី

- ដាំដំណាំចំណីសត្វ បន្ថែម
- ស្តុកចំបើង អោយបាន ១០ជង្គុង
- រៀបចំស្តុកទឹក និងពាងទឹកគ្រប់គ្រាន់

## ៥_ ព័ត៌មាន

- បង្កើនការទំនាក់ទំនង អ្នកជំនាញបច្ចេកទេសពេទ្យសត្វ

| ១_ចំណាយ | | | | | |
|---|---|---|---|---|---|
| ល.រ | ថ្នាំការពារជំងឺ | ឯកតា | ចំនួន | តម្លៃ . រៀល | សរុប . រៀល |
| ០១ | ថ្នាំការពារជំងឺសារទឹក | កំរិត | ១១២ | ៥០០ | ៥៦.០០០ |
| ០២ | ថ្នាំការពារជំងឺអុតក្តាម | កំរិត | ៥៦ | ៣.០០០ | ១៦៨.០០០ |
| ០៣ | ទំលាក់សត្វល្អិត | កំរិត | ១១២ | ១.៥០០ | ១៦៨.០០០ |
| ០៤ | ចំបើង | ជង្គុង | ៥ | ៥០.០០០ | ២៥០.០០០ |
| ០៥ | ជីអ៊ុយរ៉េចំបើងផ្លាប់ | គក្រ | ១០០ | ១.៨០០ | ១៨០.០០០ |
| ០៦ | ថ្លៃបង្កាត់ | ក្បាល | ៣៦ | ៣០.០០០ | ១.០៨០.០០០ |
| **សរុប** | | | | | ១.៩០២.០០០ |

| ២. ចំណូល | | | | | | | |
|---|---|---|---|---|---|---|---|
| ល.រ | បរិយាយ | ចំនួន | ឯកត្តា | ៣ឆ្នាំកូន២ | ចំនួនកូន | តម្លៃ/រៀល | សរុប/រៀល |
| ០១ | ចិញ្ចឹមខ្លួនឯង | កំរិត | ក្បាល | ១៩ x ២,៣ | ១២ | ១,៨០០.០០០ | ២១,៦០០.០០០ |
| ០២ | ចិញ្ចឹមប្រវាស់ | កំរិត | ក្បាល | ១៧ x ២,៣ | ១០.២ | ១,៨០០.០០០ | ៩,០០០.០០០ |
| ០៣ | ធ្យូង | កំរិត | គ.ក្រ | | ១០៩៥ | ៧០០ | ៧៦៦,៥០០ |
| ០៤ | អគ្គីសនី | | គីឡូវ៉ាត់ | | ៣៦០ | ១៨០០ | ៦៤៨,០០០ |
| ០៥ | ជីគីមី | គក្រ | ការុង | | ៦ | ៩០.០០០ | ៥៤០,០០០ |
| សរុបចំណូល | | | | | | | ៣២,៥៥៤.៥០០ |
| សរុបចំណាយ | | | | | | | ១,៩០២.០០០ |
| សរុបចំណេញ | | | | | | | ៣០,៦៥២.៥០០ |

- ទំនាក់ទំនងទីផ្សារ ដែលមានតម្លៃខ្ពស់ ( ឈ្មួញទិញគោ)
- សិក្សាស្រាវជ្រាវបន្ថែម តាមរយៈឯកសារ ទស្សនះកិច្ច
- ទំនាក់ទំនងរកពូជល្អឱ្យស្របតាមតម្រូវការទីផ្សារ
- ការចែករំលែកបទពិសោធន៏កន្លងមកមាន :
    - តាមរយៈការចែក ពូជគោប្រវាស់





 

- តាមរយៈការលក់គោទៅអចិតិជន
- តាមរយៈបទអន្តរាគមន៍ នូវបទពិសោធន៍
- តាមរយៈផ្តល់ដោយទស្សនៈកិច្ចនៅកន្លែងផ្ទាល់
- តាមរយៈការសាកសួរផ្ទាល់ និងការពិភាក្សា
- ទិសដៅ ការចិញ្ចឹមគោ ត្រូវគិតគូរ :
- ពូជ ក្រោល ចំណី ការការពារ និងការថែទាំ
- តាមដានចំណាយ និង ចំណូល
- ប្រើសក្តានុពល នៃអនុផល តាមរយៈប្រព័ន្ធផលិតកម្មចំរុះ គោ ឡជីវឧស្ម័នលាមក (ដំណាំបន្លែ,ស្រូវ) គោ

## ៦. សំណូមពរ

- សូមរដ្ឋាភិបាលនាំពូជគោល្អៗចូលពីក្រៅ ដើម្បីកែប្រែពូជដល់អ្នកចិញ្ចឹម
- គួរបង្កើតច្បាប់មិនអោយចិញ្ចឹមគោប្រលែង (ដាំដំណាំមិនបាន,ងាយទទួលជំងឺ,បាត់បង់,,,)

## ៧. ថ្លែងអំណរគុណ


- លោកប្រធានការិយាល័យផលិតកម្ម និងបសុព្យាបាល
- លោកប្រធានមន្ទីរកសិកម្មខេត្តកំពង់ឆ្នាំង ព្រមទាំងសហការី ដែលបានពន្យល់ណែនាំ និង សម្របសម្រួលដល់រូបខ្ញុំ ។



គេហដ្ឋានរបស់ កសិករ ប៊ិច ប៊ុនថន

ំ លោកប្រធាន-អនុប្រធាន នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

ំ គណៈកម្មការប្រឡងប្រណាំងកសិករឆ្នើម លោកបានសម្រេចផ្តល់អោយរូបខ្ញុំជាប់ចំណាត់ថ្នាក់ជាកសិករគំរូ ។

ំ ឯកឧត្តមបណ្ឌិត **ច័ន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានបង្កើត វេទការប្រឡងប្រណាំងកសិករឆ្នើមក្នុងការចិញ្ចឹមសត្វ ដែលជាឱកាសផ្តល់ដល់រូបខ្ញុំបានធ្វើបទបង្ហាញ និងបានផ្ទេរបទពិសោធន៍ទាំងនេះ ជូនដល់អ្នកចិញ្ចឹមផ្សេងទៀត ។